**ការច្រឡំអង្គហេតុ (mistake of fact)**

ការច្រឡំអង្គហេតុ គឺជាការដោះសារ (excuse) អាចនាំឲ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនវាលុបនូវធាតុផ្សំអត្តនោម័ត (*mens rea*) នៃបទល្មើស (offense)។

ការច្រឡំនេះ អាចកើតមាន ដូចជា ការច្រឡំជនស៊ីវិល (civilian) ថាជាយោធា (soldier) ដែលនាំឲ្យ មានការបាញ់សម្លាប់ក្នុងអំឡុងពេលធ្វើសង្គ្រាម។ ក្នុងករណីខ្លះ ការច្រឡំកើតមាន លើធាតុផ្សំតែមួយនៃបទល្មើស ដែលនឹងមិនអាចឲ្យរួចផុតពីការទទួលខុសត្រូវទាំងស្រុងនោះទេ។ ប្រសិនបើការច្រឡំថា ជនស៊ីវិលជាទាហាន ជំនួសឲ្យសម្លាប់ គេអាចឃាត់ខ្លួន និងធ្វើការឃុំពួកគេទុកសិន មុននឹងសម្លាប់។ ការសម្លាប់មុននឹងបញ្ជោក់ ជនល្មើសនៅតែទទួលខុសត្រូវចំពោះការសម្លាប់។

មានការស្នើថា ការច្រឡំនេះ អាចទទួលយកជាបានការ លុះត្រាតែវាជាការច្រឡំសមហេតុផល។ មាត្រា៣២(១) នៃលក្ខន្តិកៈ ICC ចែងថា ការច្រឡំនឹងមិនជាការដោះសារទេ ប្រសិន ជនល្មើសមានការធ្វេសប្រហែស (negligence) ក្នុងការបង្កើតនូវជំនឿដែលច្រឡំនោះ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 421-422)។